MRDC NEWSLETTER

November 2011, Issue Nr. 4




Bunong Culture in Mondulkiri Province

# ពិព័ណ៌វប្បធម៌ជនជាតិដើមភាគតិច (ពូនង) ខេត្តមណ្ឌលគិរី

# Mondulkiri's Bunong Cultural Exhibition

**By Bunthy Chey**

ដើម្បីចូលរួមក្នុងការអភិរក្ស ក៏ដូចជាលើកស្ទួយវប្បធម៌ប្រពៃណីរបស់ជនជាតិដើមភាគតិច ខេត្តមណ្ឌលគិរី ជាពិសេសជនជាតិពូនង ឲ្យមានភាពស្ថិតស្ថេរគង់វង្ស និងកាន់តែមានការទទួលស្គាល់ និងដឹងឮកាន់តែច្រើនពីមជ្ឈដ្ឋានជាតិ និងអន្តរជាតិ គម្រោងមណ្ឌលធនធានឯកសារខេត្តមណ្ឌលគិរី របស់អង្គការណូម៉ាដ នឹងមានរៀបចំកម្មវិធីតាំងពិព័ណ៌ដ៏ធំមួយ ស្តីអំពីវប្បធម៌ជនជាតិដើមភាគតិច (ពូនង) ខេត្តមណ្ឌលគិរី។ ដែលនឹងមានការអញ្ជើញចូលរួមពីភ្ញៀវកិត្តិយសថ្នាក់ដឹកនាំខេត្ត អង្គភាព/ស្ថាប័នពាក់ព័ន្ធនានា បណ្តាអង្គការជាតិ/អន្តរជាតិ ប្រជាជនតាមភូមិ សិស្សានុសិស្ស និងសាធារណៈជនទូទៅផងដែរ។

ពិធីនេះនឹងមានរៀបចំកម្មវិធីជាបន្តបន្ទាប់ដូចជា៖

- ការសម្តែងរបាំប្រពៃណីជនជាតិពូនង
- ការបញ្ចាំងខ្សែភាពយន្តឯកសារដែលស្តីពីវប្បធម៌ ប្រពៃណី ទំនៀមទម្លាប់រស់នៅរបស់ជនជាតិពូនង
- សកម្មភាពរបស់គម្រោងដែលបានអនុវត្តកន្លងមកក្នុងការចូលរួមគាំទ្រជនជាតិដើមភាគតិច
- ការដាក់តាំងផលិតផលដែលធ្វើដោយដៃរបស់ជនជាតិពូនង
- និងពិព័ណ៌បន្លែអាហារដែលនាំចេញពីព្រៃ ឬអាចនិយាយបានថាជាអាហារបែបប្រពៃណីរបស់ជនជាតិដើមភាគតិចពូនង។

ស្របពេលជាមួយគ្នានោះដែរ មណ្ឌលក៏មានរៀបចំពិធីចម្អិនម្ហូបបែបប្រពៃណីទាំងនោះជូនភ្ញៀវដែលចូលរួមក្នុងកម្មវិធី ដើម្បីភ្លក់ និងទស្សនាផងដែរ។

មិនតែប៉ុណ្ណោះ មណ្ឌលក៏នឹងមានរៀបចំការសម្តែងរឿងខ្លីក៏គួរឲ្យចាប់អារម្មណ៍មួយ ដែលមានចំណងជើងថា «ទិដ្ឋភាពភូមិយើង» បង្ហាញអំពីការផ្លាស់ប្តូរប្រពៃណី វប្បធម៌ ជំនឿក៏ដូចជារបៀបរបបនៃការរស់នៅរបស់ជនជាតិពូនង ចូលរួមសម្តែងដោយមន្ត្រីមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត និងបុគ្គលិកអង្គការណូម៉ាដ។

ឆ្លៀតក្នុងឱកាសនេះមណ្ឌលធនធានឯកសារ មានកិត្តិយសសូមគោរពអញ្ជើញ លោក-លោកស្រីដែលមានចំណាប់អារម្មណ៍ទៅលើប្រធានបទនេះ មកចូលរួមទស្សនា ភ្លក់ រសជាតិម្ហូបអាហាររបស់ជនជនពូនង និងស្វែងយល់ដោយសេរី ជាមួយកម្មវិធីតាំងពិព័ណ៌នេះដែលនឹងប្រព្រឹត្តទៅនៅក្នុងបរិវេណមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តមណ្ឌលគិរី វេលាម៉ោង៤ល្ងាច ថ្ងៃទី២៨ ខែវិច្ឆិកា ខាងមុខនេះ។

យើងខ្ញុំសង្ឃឹមថាលោក-អ្នក នឹងមានវត្តមានក្នុងកម្មវិធីនេះ ហើយកុំភ្លេចនាំមិត្តភក្តិ និងក្រុមគ្រួសារមកចូលរួមជាមួយ។



The Mondulkiri Resource and Documentation Centre (MRDC), one of the projects of Nomad RSI, is now organizing a big event, the "Mondulkiri's Bunong Cultural Exhibition" to contribute to preserve and promote the traditions, belief and cultures of the Bunong become worldwide known. Various guests of honor from the provincial level, line departments, national/international NGOs, villagers, students as well as the public will participate in this event.

Many different activities are planned, including:
- A traditional Bunong musical performance show
- A movie screening related to the traditional life style of the Bunong
- A slide show of the activities implemented by the MRDC during the past year
- Display of Bunong handicraft products
- Exhibition about "Food from the Forest"

During the event, we will have a food cooking show performed by several Bunong chefs from the communities and everybody is invited to visit and try the delicious Bunong dishes, made from food from the forest.

The highlight of the evening is a theatre show titled "Aspects of our village" regarding the changes of Bunong culture. Actors include staff from the Department of Culture and Fine Arts and Nomad RSI.

The MRDC would like to invite you to join this eventful evening, to enjoy the various shows, displays and exhibitions and to test the exquisite Bunong food from the forest. The event is free of admission and it will be held at the yard of the Department of Culture and Fine Arts on the 28$^{th}$ of November 2011, starting at 4:00 pm.

We hope to see you there and bring your friends and family!



Nomad's theater shows in the villages

